**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩

ក្នុងក្របខណ្ឌទូទាំងប្រទេស(គ.វ.ក-១៩)

លេខ......៧៤៣/២១.....គ.វ.ក-១៩

ថ្ងៃ អង្គារ ៨រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ,ថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០២១

## សេចក្តីជូនព័ត៌មាន

## ស្តីពី

## ការចាក់វ៉ាក់សាំងកូវីដ-១៩ (អាស្ត្រាហ្សេនីកា) ដូសជំរុញ ជូនដល់ប្រជាពលរដ្ឋដែលបានចាក់វ៉ាក់សាំងកូវីសែល ដូសទី១ និងដូសទី២រួចរាល់

គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.វ.ក-១៩) សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឱ្យបានជ្រាបថា គ.វ.ក-១៩ នឹងផ្តល់ការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ ដោយប្រើប្រាស់វ៉ាក់សាំងអាស្ត្រាហ្សេនីកា ជូនដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ មន្ត្រីអង្គការសហប្រជាជាតិ មន្ត្រី និងបុគ្គលិកស្ថានទូតនានា មន្ត្រី និងបុគ្គលិកអង្គការជាតិ និងអន្តរជាតិ ប្រជាពលរដ្ឋរួមទាំងជនវ័យចាស់ ដែលបានចាក់វ៉ាក់សាំងកូវីសែល (Covishield) ដូសទី១ និងដូសទី២រួចរាល់ ព្រមទាំងស្វាមី ឬភរិយា របស់ពួកគាត់ដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី១ និងដូសទី២រួចរាល់ ដែលនឹងចាប់ផ្តើមពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១ ដូចខាងក្រោម៖

### ក. ការចាក់វ៉ាក់សាំងអាស្ត្រាហ្សេនីកាដូសជំរុញ ជូនដល់មន្ត្រីរាជការថ្នាក់ជាតិ៖

ចំពោះថ្នាក់ដឹកនាំ មន្ត្រីរាជការថ្នាក់ជាតិ មន្ត្រីអង្គការសហប្រជាជាតិ មន្ត្រី និងបុគ្គលិកស្ថានទូតនានា មន្ត្រី និងបុគ្គលិកអង្គការជាតិ និងអន្តរជាតិ ដែលបានចាក់វ៉ាក់សាំងកូវីសែលដូសទី១ និងដូសទី២រួចរាល់ ព្រមទាំងស្វាមី ឬភរិយា របស់ពួកគាត់ ដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី១ និងដូសទី២រួចរាល់ ដែលមានគម្លាតចាប់ពី៤ ទៅ៦ខែឡើងបន្ទាប់ពីបានចាក់វ៉ាក់សាំងដូសមូលដ្ឋាន សូមអញ្ជើញទៅចាក់វ៉ាក់សាំងអាស្ត្រាហ្សេនីកាដូសជំរុញ នៅតាមមន្ទីរពេទ្យជាតិនានា ដែលមានទីតាំង កាលបរិច្ឆេទ និងពេលវេលាដូចខាងក្រោម៖

**១. មន្ទីរពេទ្យកាល់ម៉ែត និងមន្ទីរពេទ្យព្រះអង្គឌួង៖**

- ចំពោះថ្នាក់ដឹកនាំរាជរដ្ឋាភិបាល ថ្នាក់ដឹកនាំព្រឹទ្ធសភា និងសមាជិកព្រឹទ្ធសភា ថ្នាក់ដឹកនាំរដ្ឋសភា និងសមាជិករដ្ឋសភា និងឥស្សរជនដែលមានតួនាទី ជាឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ឬមានឋានៈស្មើ ហើយបានចាក់វ៉ាក់សាំង កូវីសែលដូសទី១ និងដូសទី២រួចរាល់ ព្រមទាំងស្វាមី ឬភរិយា របស់ពួកគាត់ដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី១ និងដូសទី២រួចរាល់ ដែលមានគម្លាតចាប់ពី៤ ទៅ៦ខែឡើងបន្ទាប់ពីបានចាក់វ៉ាក់សាំងដូសមូលដ្ឋាន សូមអញ្ជើញទៅចាក់វ៉ាក់សាំងអាស្ត្រាហ្សេនីកាដូសជំរុញ នៅមន្ទីរពេទ្យកាល់ម៉ែត។
- ចំពោះឥស្សរជនដែលជាអនុរដ្ឋលេខាធិការ អគ្គនាយក អគ្គនាយករង ឬមានឋានៈស្មើ ព្រមទាំងស្វាមី ឬភរិយា របស់ពួកគាត់ដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី១ និងដូសទី២ រួចរាល់ ដែលមានគម្លាតចាប់ពី៤ ទៅ៦ខែឡើងបន្ទាប់ពីបានចាក់វ៉ាក់សាំងដូសមូលដ្ឋាន សូមអញ្ជើញទៅចាក់វ៉ាក់សាំងដូសជំរុញ នៅមន្ទីរពេទ្យព្រះអង្គឌួង។

ការចាក់វ៉ាក់សាំងអាស្ត្រាហ្សេនីកាដូសជំរុញ ជូនដល់ក្រុមគោលដៅខាងលើ នឹងត្រូវរៀបចំតាមពេលវេលា និងកាលបរិច្ឆេទ ដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ៤ | -អង្គភាពប្រឆាំងអំពើពុករលួយ | ៩ ដល់ ១១ កញ្ញា ឆ្នាំ២០២១ | ម៉ោង០៨:០០ ដល់១១:០០ |
| ៥ | -ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | | ម៉ោង១៤:០០ ដល់១៧:០០ |
| ៦ | -ក្រសួងពាណិជ្ជកម្ម | ១២ ដល់ ១៤ កញ្ញា ឆ្នាំ២០២១ | ម៉ោង០៨:០០ ដល់១១:០០ |
| ៧ | -ក្រសួងធម្មការ និងសាសនា | | ម៉ោង១៤:០០ ដល់១៧:០០ |
| ៨ | -ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ១៥ ដល់ ១៧ កញ្ញា ឆ្នាំ២០២១ | ម៉ោង០៨:០០ ដល់១១:០០ |
| ៩ | -ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | | ម៉ោង១៤:០០ ដល់១៧:០០ |
| ១០ | -ក្រសួងធនធានទឹក និងឧតុនិយម | ១៨ ដល់ ២១ កញ្ញា ឆ្នាំ២០២១ | ម៉ោង០៨:០០ ដល់១១:០០ |
| ១១ | -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | | ម៉ោង១៤:០០ ដល់១៧:០០ |
| ១២ | -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ២២ ដល់ ២៤ កញ្ញា ឆ្នាំ២០២១ | ម៉ោង០៨:០០ ដល់១១:០០ |
| ១៣ | -ក្រសួងរ៉ែ និងថាមពល | | ម៉ោង១៤:០០ ដល់១៧:០០ |
| ១៤ | -អគ្គិសនីកម្ពុជា | ២៥ ដល់ ២៦ កញ្ញា ឆ្នាំ២០២១ | ម៉ោង០៨:០០ ដល់១១:០០ |
| ១៥ | -អាជ្ញាធរប្រេងកាត | | ម៉ោង១៤:០០ ដល់១៧:០០ |
| ១៥ | -អាកាសចរស៊ីវិល | ២៧ ដល់ ២៨ កញ្ញា ឆ្នាំ២០២១ | ម៉ោង០៨:០០ ដល់១១:០០ |
| ១៦ | -អាជ្ញាធរផ្សេងៗ | | ម៉ោង១៤:០០ ដល់១៧:០០ |

**ខ. ការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ ជូនដល់មន្ត្រីអង្គការសហប្រជាជាតិ មន្ត្រី និងបុគ្គលិកស្ថានទូតនានា មន្ត្រី និងបុគ្គលិកអង្គការជាតិ និងអន្តរជាតិ ៖**

ចំពោះមន្ត្រីអង្គការសហប្រជាជាតិ មន្ត្រី បុគ្គលិកស្ថានទូត ស្ថានកុងស៊ុល ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា មន្ត្រី និងបុគ្គលិកអង្គការជាតិ អន្តរជាតិ និងដៃគូផ្សេងៗទៀត ដែលបានចាក់វ៉ាក់សាំងកូវីសែលដូសទី១ និងទី២រួចរាល់ ព្រមទាំងស្វាមី ឬភរិយា របស់ពួកគាត់ដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី១ និងដូសទី២រួចរាល់ នៅតាមមន្ទីរពេទ្យជាតិនានា ដែលមានគម្លាតចាប់ពី៤ ទៅ៦ខែឡើងបន្ទាប់ពីបានចាក់វ៉ាក់សាំងដូសមូលដ្ឋាន សូមអញ្ជើញទៅចាក់វ៉ាក់សាំងអាស្ត្រាហ្សេនីកាដូសជំរុញនៅ**មន្ទីរពេទ្យកាល់ម៉ែត** តាមពេលវេលា និងកាលបរិច្ឆេទដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះអង្គភាព | កាលបរិច្ឆេទ | ពេលវេលា |
|---|---|---|---|
| ១ | -មន្ត្រីអង្គការសហប្រជាជាតិ មន្ត្រី និងបុគ្គលិកស្ថានទូត ស្ថានកុងស៊ុល និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា | ២៩ ដល់ ៣០ កញ្ញា ឆ្នាំ២០២១ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ២ | -មន្ត្រី និងបុគ្គលិកអង្គការជាតិ អន្តរជាតិ និងដៃគូផ្សេងៗទៀត | ០១ ដល់ ០២ តុលា ឆ្នាំ២០២១ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |

**គ. ការចាក់វ៉ាក់សាំងអាស្ត្រាហ្សេនីកាដូសជំរុញ ដល់មន្ត្រីរាជការ និងប្រជាពលរដ្ឋក្រោមឱវាទរដ្ឋបាលរាជធានីភ្នំពេញ៖**

ចំពោះមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា ក្រោមឱវាទរដ្ឋបាលរាជធានីភ្នំពេញ និងប្រជាពលរដ្ឋទូទៅ ដែលបានចាក់វ៉ាក់សាំងកូវីសែល ដូសទី១ និងដូសទី២រួចរាល់ ព្រមទាំងស្វាមី ឬភរិយា របស់ពួកគាត់ដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី១ និងដូសទី២រួចរាល់ ដែលមានគម្លាតចាប់ពី៤ ទៅ៦ខែឡើងបន្ទាប់ពីបានចាក់វ៉ាក់សាំងដូសមូលដ្ឋាន នឹងត្រូវរៀបចំចាក់ជូនដោយរដ្ឋបាលរាជធានីភ្នំពេញ ដែលរដ្ឋបាលរាជធានីភ្នំពេញនឹងចេញសេចក្តីជូនព័ត៌មានពីទីតាំង នៃការចាក់វ៉ាក់សាំងដូសជំរុញនេះផ្សព្វផ្សាយជូនសាធារណជនជ្រាប ដោយចាប់ផ្តើមចាក់ចាប់ពីថ្ងៃទី០៦ ខែកញ្ញា រហូតដល់ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១។

| ល.រ | ឈ្មោះក្រសួង និងស្ថាប័ន | កាលបរិច្ឆេទ | ពេលវេលា |
| --- | --- | --- | --- |
| ១ | -ឧត្តមក្រុមប្រឹក្សាអង្គចៅក្រម | ០៦ ដល់ ០៩ កញ្ញា ២០២១ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ២ | -ក្រសួងព្រះបរមរាជវាំង | | |
| ៣ | -ព្រឹទ្ធសភា | | |
| ៤ | -ទីស្តីការគណៈរដ្ឋមន្ត្រី | | |
| ៥ | -រដ្ឋសភា | | |
| ៦ | -ក្រសួងសុខាភិបាល | ១០ ដល់ ១២ កញ្ញា ២០២១ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ៧ | -ក្រុមប្រឹក្សាធម្មនុញ្ញ | | |
| ៨ | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | |
| ៩ | -ក្រសួងអប់រំ យុវជន និងកីឡា | | |
| ១០ | -ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ១៣ ដល់ ១៤ កញ្ញា ២០២១ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ១១ | -ក្រសួងព័ត៌មាន | | |
| ១២ | -តុលាការកំពូល | | |
| ១៣ | -សាលាឧទ្ធរណ៍ភ្នំពេញ | | |
| ១៤ | -ធនាគារជាតិ នៃកម្ពុជា | | |
| ១៥ | -ក្រសួងមហាផ្ទៃ | ១៥ ដល់ ១៧ កញ្ញា ២០២១ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ១៦ | -ក្រសួងការពារជាតិ | | |
| ១៧ | -ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | | |
| ១៨ | -ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | | |
| ១៩ | -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ១៨ ដល់ ១៩ កញ្ញា ២០២១ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ២០ | -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | |
| ២១ | -គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) | | |
| ២២ | -ក្រសួងផែនការ | | |
| ២៣ | -ក្រសួងអភិវឌ្ឍន៍ជនបទ | ២០ ដល់ ២១ កញ្ញា ២០២១ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ២៤ | -អាជ្ញាធរសវនកម្មជាតិ | | |
| ២៥ | -ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | | |
| ២៦ | -ក្រសួងសាធារណការ និងដឹកជញ្ជូន | | |
| ២៧ | -ក្រសួងបរិស្ថាន | | |
| ២៨ | -អង្គភាពប្រឆាំងអំពើពុករលួយ | ២២ ដល់ ២៣ កញ្ញា ២០២១ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ២៩ | -ក្រសួងកិច្ចការនារី | | |
| ៣០ | -ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | | |
| ៣១ | -ក្រសួងពាណិជ្ជកម្ម | | |
| ៣២ | -ក្រសួងមុខងារសាធារណៈ | | |
| ៣៣ | -កាកបាទក្រហមកម្ពុជា | | |

| | | | |
|---|---|---|---|
| ៣៤ | -ក្រសួងទេសចរណ៍ | ២៤ ដល់ ២៦ កញ្ញា ២០២១ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ៣៥ | -ក្រសួងធម្មការ និងសាសនា | | |
| ៣៦ | -ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | | |
| ៣៧ | -ក្រសួងធនធានទឹក និងឧតុនិយម | | |
| ៣៨ | -ក្រសួងយុត្តិធម៌ | | |
| ៣៩ | -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | | |
| ៤០ | -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | | |
| ៤១ | -ក្រសួងរ៉ែ និងថាមពល | | |
| ៤២ | -អគ្គិសនីកម្ពុជា | ២៧ ដល់ ២៨ កញ្ញា ២០២១ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ៤៣ | -អាជ្ញាធរប្រេងកាត | | |
| ៤៤ | -អាកាសចរស៊ីវិល | | |
| ៤៥ | -អាជ្ញាធរផ្សេងៗ | | |

២. មន្ទីរពេទ្យកុមារជាតិ៖

មន្ទីរពេទ្យកុមារជាតិ ជាទីតាំងចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ ជូនដល់មន្ត្រីរាជការចាប់ពីថ្នាក់ប្រធាននាយកដ្ឋានចុះ និងមន្ត្រីជាប់កិច្ចសន្យាថ្នាក់ជាតិ ដែលបានចាក់វ៉ាក់សាំងកូវីសែលដូសទី១ និងទី២រួចរាល់ ព្រមទាំងស្វាមី ឬភរិយា របស់ពួកគាត់ ដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី១ និងដូសទី២រួចរាល់ ដែលមានគម្លាតចាប់ពី៤ ទៅ៦ខែឡើងបន្ទាប់ពីបានចាក់វ៉ាក់សាំងដូសមូលដ្ឋាន នៃក្រសួង-ស្ថាប័នចំនួន១១ ដូចមានក្នុងតារាងខាងក្រោម៖

| លរ | ឈ្មោះក្រសួង និងស្ថាប័ន | កាលបរិច្ឆេទ | ពេលវេលា |
|---|---|---|---|
| ១ | -ក្រសួងសុខាភិបាល | ០៦ ដល់ ០៨ កញ្ញា ឆ្នាំ២០២១ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ២ | -ក្រសួងមហាផ្ទៃ | ០៩ ដល់ ១១ កញ្ញា ឆ្នាំ២០២១ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ៣ | -ក្រសួងការពារជាតិ | ១២ ដល់ ១៤ កញ្ញា ឆ្នាំ២០២១ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ៤ | -សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១៥ ដល់ ១៧ កញ្ញា ឆ្នាំ២០២១ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ៥ | -ធនាគារជាតិ នៃកម្ពុជា | | |
| ៦ | -ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | ១៨ ដល់ ២០ កញ្ញា ឆ្នាំ២០២១ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ៧ | -ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | | |
| ៦ | -ក្រសួងអប់រំ យុវជន និងកីឡា | ២១ ដល់ ២៥ កញ្ញា ឆ្នាំ២០២១ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ៧ | -ក្រសួងមុខងារសាធារណៈ | | |
| ៨ | -កាកបាទក្រហមកម្ពុជា | | |
| ៩ | -ក្រសួងយុត្តិធម៌ | ២៦ ដល់ ២៨ កញ្ញា ឆ្នាំ២០២១ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ១០ | -ក្រសួងផែនការ | | |
| ១១ | -គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) | | |

៣. មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក៖

មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក ជាទីតាំងចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ ជូនដល់មន្ត្រីរាជការ ចាប់ពីថ្នាក់ប្រធាននាយកដ្ឋានចុះ មន្ត្រីជាប់កិច្ចសន្យាថ្នាក់ជាតិ ព្រមទាំងស្វាមី ឬភរិយា របស់ពួកគាត់ដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី១ និងដូសទី២រួចរាល់ ដែលមានគម្លាតចាប់ពី៤ ទៅ៦ខែឡើងបន្ទាប់ពីបានចាក់វ៉ាក់សាំងដូសមូលដ្ឋាន នៃក្រសួង-ស្ថាប័នចំនួន១៥ ដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះក្រសួង និងស្ថាប័ន | កាលបរិច្ឆេទ | ពេលវេលា |
|---|---|---|---|
| ១ | -ឧត្តមក្រុមប្រឹក្សាអង្គចៅក្រម | ០៦ ដល់ ០៩ កញ្ញា ឆ្នាំ២០២១ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ២ | -ក្រសួងព្រះបរមរាជវាំង | | |
| ៣ | -ព្រឹទ្ធសភា | | |
| ៤ | -ក្រុមប្រឹក្សាធម្មនុញ្ញ | ១០ ដល់ ១២ កញ្ញា ឆ្នាំ២០២១ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ៥ | -រដ្ឋសភា | | |
| ៦ | -ទីស្តីការគណៈរដ្ឋមន្ត្រី | ១៣ ដល់ ១៧ កញ្ញា ឆ្នាំ២០២១ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ៧ | -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | |
| ៨ | -តុលាការកំពូល | ១៨ ដល់ ២០ កញ្ញា ឆ្នាំ២០២១ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ៩ | -សាលាឧទ្ធរណ៍ភ្នំពេញ | | |
| ១០ | -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | | |
| ១១ | -ក្រសួងសាធារណការ និងដឹកជញ្ជូន | ២១ ដល់ ២៣ កញ្ញា ឆ្នាំ២០២១ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ១២ | -ក្រសួងកិច្ចការនារី | | |
| ១៣ | -ក្រសួងទេសចរណ៍ | ២៤ ដល់ ២៨ កញ្ញា ឆ្នាំ២០២១ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ១៤ | -ក្រសួងព័ត៌មាន | | |
| ១៥ | -ក្រសួងបរិស្ថាន | | |

៤. មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត៖

មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ជាទីតាំងចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ ជូនដល់មន្ត្រីរាជការចាប់ពីថ្នាក់ប្រធាននាយកដ្ឋានចុះ និងមន្ត្រីជាប់កិច្ចសន្យាថ្នាក់ជាតិ ដែលបានចាក់វ៉ាក់សាំងកូវីសែលដូសទី១ និងទី២រួចរាល់ ព្រមទាំងស្វាមី ឬភរិយារបស់ពួកគាត់ដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី១ និងដូសទី២រួចរាល់ ដែលមានគម្លាតចាប់ពី៤ ទៅ៦ខែឡើងបន្ទាប់ពីបានចាក់វ៉ាក់សាំងដូសមូលដ្ឋាន នៃក្រសួង-ស្ថាប័នចំនួន១៦ ដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះក្រសួង និងស្ថាប័ន | កាលបរិច្ឆេទ | ពេលវេលា |
|---|---|---|---|
| ១ | -ក្រសួងអភិវឌ្ឍន៍ជនបទ | ០៦ ដល់ ០៨ កញ្ញា ឆ្នាំ២០២១ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ២ | -អាជ្ញាធរសវនកម្មជាតិ | | |
| ៣ | -ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | | |

### ឃ.ការចាក់វ៉ាក់សាំងអាស្ត្រាហ្សេនីកាដូសជំរុញ ដល់មន្ត្រីរាជការ និងប្រជាពលរដ្ឋក្រោមឱវាទរដ្ឋបាលខេត្តកណ្តាល និងខេត្តព្រះសីហនុ៖

ចំពោះមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា និងប្រជាពលរដ្ឋទូទៅ ដែលបានចាក់វ៉ាក់សាំងកូវីសែល ដូសទី១ និងដូសទី២រួចរាល់ ព្រមទាំងស្វាមី ឬភរិយា របស់ពួកគាត់ដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី១ និងដូសទី២រួចរាល់ ដែលមានគម្លាតចាប់ពី៤ ទៅ៦ខែឡើងបន្ទាប់ពីបានចាក់វ៉ាក់សាំងដូសមូលដ្ឋាន ក្រោមឱវាទរដ្ឋបាលខេត្តកណ្តាល និងខេត្តព្រះសីហនុ នឹងត្រូវរៀបចំចាក់ជូនដោយរដ្ឋបាលខេត្តទាំង២នេះ ហើយរដ្ឋបាលខេត្តកណ្តាល និងខេត្តព្រះសីហនុ នឹងចេញសេចក្តីជូនព័ត៌មានពីទីតាំងនៃការចាក់វ៉ាក់សាំងដូសជំរុញនេះផ្សព្វផ្សាយជូនសាធារណជនជ្រាប ដោយចាប់ផ្តើមចាក់ចាប់ពីថ្ងៃទី០៦ ខែកញ្ញា រហូតដល់ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១។

### ង. លក្ខខណ្ឌក្នុងការចាក់វ៉ាក់សាំងដូសជំរុញ៖

អ្នកដែលអាចចាក់វ៉ាក់សាំងដូសជំរុញ ដោយប្រើប្រាស់វ៉ាក់សាំងអាស្ត្រាហ្សេនីកាអំឡុងពេលនេះ ត្រូវគោរពទៅតាមលក្ខខណ្ឌដូចខាងក្រោម៖

- អ្នកដែលបានចាក់វ៉ាក់សាំងកូវីសែល ដូសទី១ និងដូសទី២រួចរាល់ ដែលមានគម្លាតចាប់ពី៤ ទៅ៦ខែឡើងបន្ទាប់ពីបានចាក់វ៉ាក់សាំងដូសមូលដ្ឋាន ។
- ជាស្វាមី ឬភរិយា នៃអ្នកដែលបានចាក់វ៉ាក់សាំងកូវីសែលខាងលើ ហើយបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី១ និងដូសទី២រួចរាល់ ដែលមានគម្លាតចាប់ពី៤ ទៅ៦ខែឡើងបន្ទាប់ពីបានចាក់វ៉ាក់សាំងដូសមូលដ្ឋាន ។

### ច. ឯកសារត្រូវភ្ជាប់ជាមួយនៅពេលទៅចាក់វ៉ាក់សាំងដូសជំរុញ៖

ចំពោះអ្នកដែលត្រូវចាក់វ៉ាក់សាំងដូសជំរុញ ក្នុងអំឡុងពេលនេះត្រូវភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

- ប័ណ្ណចាក់វ៉ាក់សាំងកូវីដ-១៩
- ប័ណ្ណសម្គាល់ខ្លួនមន្ត្រីរាជការ ឬ ប័ណ្ណសម្គាល់មន្ត្រីជាប់កិច្ចសន្យា (ចំពោះមន្ត្រីរាជការថ្នាក់ជាតិ)
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ ឯកសារដែលប្រើប្រាស់ក្នុងការចុះឈ្មោះកាលពីចាក់វ៉ាក់សាំងដូសទី១
- សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬសំបុត្រអាពាហ៍ពិពាហ៍ ដែលបញ្ជាក់ថាជាស្វាមី ឬភរិយា នៃអ្នកដែលបានចាក់វ៉ាក់សាំងកូវីសែលខាងលើ។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ គ.វ.ក-១៩ សូមអំពាវនាវដល់ ក្រុមគោលដៅដូចបានជម្រាបជូនខាងលើ សូមអញ្ជើញទៅចាក់វ៉ាក់សាំងអាស្ត្រាហ្សេនីកាដូសជំរុញ ទៅតាមទីតាំង និងកាលបរិច្ឆេទខាងលើឱ្យបានគ្រប់គ្នា។ ទន្ទឹមគ្នានេះដែរ ទោះបីជាបុគ្គលម្នាក់ៗបានទទួលការចាក់វ៉ាក់សាំងរួចរាល់ ឬចាក់វ៉ាក់សាំងដូសជំរុញ ឬដូសទី៣រួចហើយក្តី ក៏ត្រូវបន្តអនុវត្តនូវវិធានការ «៣ការពារ» (ពាក់ម៉ាស់ លាងដៃញឹកញាប់ និងរក្សាគម្លាតសុវត្ថិភាពបុគ្គលពីមួយម៉ែត្រកន្លះឡើងទៅ) និង «៣កុំ» (កុំទៅកន្លែងដែលមានមនុស្សច្រើនកុះករ កុំទៅកន្លែងដែលបិទជិតគ្មានខ្យល់ចេញចូល កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា កុំកៀកស្មាគ្នា) តាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក៏ដូចជាបន្តរួមគ្នាអនុវត្តតាមយុទ្ធនាការជាតិក្រោមប្រធានបទ «រួមគ្នាទទួលខុសត្រូវទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩» ដើម្បីចូលរួមទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងសហគមន៍ នៃប្រទេសកម្ពុជា។



ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរសព្ទ-ទូរសារ៖ (៨៥៥-២៣) ៨៨៤ ៩០៩ / ៨៨៤ ៩០៤

ប្រសិនបើបងប្អូនប្រជាពលរដ្ឋមានចម្ងល់ពាក់ព័ន្ធទៅនឹងការចាក់វ៉ាក់សាំងកូវីដ-១៩ (អាស្ត្រាហ្សេនីកា) ដូសជំរុញ សូមទំនាក់ទំនងមកកាន់លេខទូរស័ព្ទខាងក្រោម៖

ក-ក្រុមការងារទំនាក់ទំនងសាធារណៈ /លេខាធិការដ្ឋាន៖

| | | |
|---|---|---|
| ០១២ ៩៨៩ ០៨៥ | ០៨៩ ៩៨០ ៦៦៦ | ០១២ ៧៧៧ ៧៦០ |

ខ-ក្រុមការងារចុះឈ្មោះ និងប្រព័ន្ធព័ត៌មានវិទ្យា៖

| | | |
|---|---|---|
| ០១២ ៨៩៧ ០៤៣ | ០៦៨ ៩០៦ ៦៦៦ | ០១២ ៨៦៨ ៦៤០ |

គ-ក្រុមការងារសុវត្ថិភាពវ៉ាក់សាំង និងប្រាស្រ័យទាក់ទងហានិភ័យ៖

| | | |
|---|---|---|
| ០១២ ៨៨៧ ៣៨៧ | ០១២ ៨៣៦ ៨៦៨ | ០១២ ៨៩១ ៥២៧ |

**រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មការចំពោះកិច្ច**
**ចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.ច.ក-១៩)**

វេជ្ជ. ឱ វណ្ណឌីន



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរសព្ទ-ទូរសារ៖ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩